វាយសារឡើងវិញបកប្រែពីឯកសារផ្លូវការ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១២ អនក្រ.បក ១៨ កុម្ភៈ ១៩៩៨

# អនុក្រឹត្យ

# ស្តីពី

# ការរៀបចំ និងការប្រព្រឹត្តទៅ របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

# រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជ រដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ ព្រះរាជ្យក្រឹត្យ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
- តាមការអនុម័តរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី ២២ ខែ មករា ឆ្នាំ១៩៩៨

# សំរេច

# ជំពូក ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

អនុក្រឹត្យនេះ រៀបចំបណ្តាអង្គភាពនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងកំណត់ បេសកកម្មរបស់ រដ្ឋលេខាធិការដ្ឋាន និងមុខការនៃអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអាកាសយានដ្ឋាន ស៊ីវិល ។

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ត្រូវបានដឹកនាំដោយអនុរដ្ឋលេខាធិការមួយរូប ។

# ជំពូក ២
# បេសកកម្ម និងរចនាសម្ព័ន្ធ

**មាត្រា ២.–**

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ត្រូវបាននាយករដ្ឋមន្ត្រីប្រគល់ បេសកកម្មអោយ ដឹកនាំ និងគ្រប់គ្រងវិស័យអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.–**

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល មានមុខងារ និងភារកិច្ចដូចតទៅ :

- អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីវិស័យអាកាសចរណ៍ស៊ីវិល ។
- ចងក្រង និងអនុវត្តបទប្បញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធ ដល់វិស័យអាកាសចរស៊ីវិលជាតិ និង អន្តរជាតិ ។
- ទទួលខុសត្រូវ ក្នុងការធ្វើនិតិសម្បទា និងការអភិវឌ្ឍអាកាសយានដ្ឋានទាំងអស់ នៅទូទាំង ប្រទេស ដោយធ្វើការសិក្សាស្រាវជ្រាវ កសាងប្លង់មេ (Master Plan) និងកសាងទិសដៅ នៃការអភិវឌ្ឍអាកាស យានដ្ឋានសំរាប់រយៈពេល ២០ ឆ្នាំ ។
- ពិនិត្យ និងផ្តល់ការណែនាំលើរាល់សេចក្តីស្នើសុំ ធ្វើការអភិវឌ្ឍអាកាសយានដ្ឋានរបស់អ្នក វិនិយោគ បរទេសឬក្នុងស្រុក ។
- ត្រួតពិនិត្យ និងទទួលខុសត្រូវលើរាល់ការងារសាងសង់អាកាសយានដ្ឋាន ។
- ផ្លាស់ប្តូរបទពិសោធន៍ និងបច្ចេកវិទ្យាទំនើប រវាងអ្នកជំនាញការបរទេស ដែលចូលមកជួយ ធ្វើការនៅកម្ពុជា ជាមួយអ្នកឯកទេសខ្មែរ ។
- គ្រប់គ្រងលើហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានស៊ីវិល និងការពារបរិដ្ឋានជុំវិញ ។
- គ្រប់គ្រងការធ្វើប្រតិបត្តិការ អាជីវកម្មលើអាកាសយានដ្ឋានស៊ីវិល ។

- បង្កើតសេវាកម្មលើការងារត្រួតពិនិត្យចរាចរ គ្រប់គ្រងប្រើប្រាស់ដែលអាកាស ទូរគមនាគមន៍អាកាសចរណ៍ កំណត់តំបន់ ហាមឃាត់ និងធានាសេវាកម្មឧតុនិយមអាកាសចរណ៍ស៊ីវិល។
- ត្រួតពិនិត្យ និងធានាសុវត្ថិភាព សន្តិសុខរបស់វិស័យអាកាសចរស៊ីវិល ដោយសហការជាមួយអាជ្ញាធរ ពាក់ព័ន្ធ។
- រៀបចំបទបញ្ជា បទប្បញ្ញត្តិនិងត្រួតពិនិត្យការដឹកជញ្ជូនតាមផ្លូវអាកាស របស់ក្រុមហ៊ុនអាកាសចរណ៍។
- ត្រួតពិនិត្យ និងចេញវិញ្ញាបនបត្រប្រតិបត្តិការផ្លូវអាកាសដល់ក្រុមហ៊ុនសេវាកម្មអាកាសចរណ៍ អ្នកអាកាសយានិក អ្នកបច្ចេកបទេសរោងជាង អ្នកបច្ចេកទេសថែរក្សាអាកាសយានព្រមទាំងធ្វើការចុះបញ្ជី អាកាសយានស៊ីវិលគ្រប់ប្រភេទ។
- គ្រប់គ្រងប្រព័ន្ធវិទ្យុអេឡិចត្រូនិក ដែលបំរើអោយសេវាកម្មចរាចរដែនអាកាស និងសិក្សាពីតំរូវការរបស់ប្រព័ន្ធ។

**មាត្រា ៤.-**

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល មានរចនាសម្ព័ន្ធដូចតទៅ :

- អគ្គនាយកដ្ឋានអាកាសចរណ៍ស៊ីវិលមាន :
- នាយកដ្ឋានប្រតិបត្តិការហោះហើរ និងសុវត្ថិភាពហោះហើរ
- នាយកដ្ឋានវិស្វកម្មអេឡិចត្រូនិក
- នាយកដ្ឋានវិស្វកម្មអាកាសយានដ្ឋាន
- នាយកដ្ឋានដឹកជញ្ជូនផ្លូវអាកាស
- នាយកដ្ឋានសន្តិសុខ
- នាយកដ្ឋានផែនការនីតិកម្ម
- អាកាសយានដ្ឋានអន្តរជាតិពោធិចិនតុងមានឋានៈស្មើនាយកដ្ឋាន
- អាកាសយានដ្ឋានមូលដ្ឋាន
- អធិការដ្ឋាន
- នាយកដ្ឋានរដ្ឋបាល បុគ្គលិក
- នាយកដ្ឋានផ្គត់ផ្គង់ ហិរញ្ញវត្ថុ

អង្គការលេខរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ។

# ជំពូក ៣
# អគ្គនាយកដ្ឋានអាកាសចរស៊ីវិល

## មាត្រា ៥.-

អគ្គនាយកដ្ឋានអាកាសចរស៊ីវិលទទួលបន្ទុក ដឹកនាំ ទំនាក់ទំនង សំរបសំរួលគ្រប់គ្រង សកម្មភាពប្រតិបត្តិការហោះហើរ សុវត្ថិភាពហោះហើរ វិស្វកម្មអេឡិចត្រូនិក វិស្វកម្ម អាកាសយានដ្ឋាន ការដឹកជញ្ជូនផ្លូវអាកាស ការងារសន្តិសុខអាកាសចរណ៍ និងផែនការអភិវឌ្ឍ ។

អគ្គនាយកដ្ឋានដឹកនាំដោយអគ្គនាយកមួយរូប និងមានអគ្គនាយករងជាជំនួយការ ។

អគ្គនាយកដ្ឋានអាកាសចរណ៍ស៊ីវិល មាននាយកដ្ឋានចំនួន ០៧ និងអាកាសយានដ្ឋានដូចមានចែងក្នុងមាត្រាខាងក្រោម ។

## មាត្រា ៦.-

នាយកដ្ឋានប្រតិបត្តិការហោះហើរ និងសុវត្ថិភាពហោះហើរទទួលបន្ទុក :

- ត្រួតពិនិត្យ គ្រប់គ្រងសេវាកម្មចរាចរដែនអាកាស ។
- សំរបសំរួលជាមួយគណៈកម្មការក្នុងប្រទេស គឺគណៈកម្មការសំរាប់រុករក និងជួយសង្គ្រោះយន្តហោះ និងនាវាពេលមានឧប្បត្តិហេតុ និងជាមួយគណៈកម្មការអន្តរជាតិ ដើម្បីដោះស្រាយក្នុងការជួយសង្គ្រោះ ពេលអាកាសយាន និង នាវាមានឧប្បត្តិហេតុ ។
- គ្រប់គ្រងការងារសង្គ្រោះអគ្គិភ័យ សហការណ៍ជាមួយអង្គភាពអគ្គិភ័យខេត្ត ក្រុង ដើម្បីជួយសង្គ្រោះ ពន្លត់អគ្គិភ័យនៅក្នុង និងជុំវិញអាកាសយានដ្ឋាន ។
- គ្រប់គ្រងទទួល និងផ្សព្វផ្សាយលើសេវាកម្មពត៌មានអាកាសចរណ៍ទាំងក្នុងប្រទេស និងអន្តរជាតិដែលពាក់ព័ន្ធ លើការងារហោះហើរ ឆ្លងកាត់ និងចុះចត ។
- ចងក្រងបទដ្ឋានហោះហើរសំរាប់អាកាសយានដ្ឋានស៊ីវិល កំណត់តំបន់ហាមឃាត់ តំបន់គ្រោះថ្នាក់កំពស់ហោះហើរ និងត្រួតពិនិត្យការងារនេះ ។
- ធានាផ្តល់សេវាកម្ម ពត៌មានឧតុនិយមអាកាសចរណ៍ ។
- ត្រួតពិនិត្យ និងចេញវិញ្ញាបនបត្រជូនអ្នកអាកាសយានិក អ្នកបច្ចេកទេសរោងជាងអ្នកបច្ចេកទេស ថែរក្សាអាកាសយាន និងត្រួតពិនិត្យគុណភាពបច្ចេកទេស លើការងារដែលពាក់ព័ន្ធ ។
- ចេញវិញ្ញាបនបត្រប្រតិបត្តិការផ្លូវអាកាស ដល់ក្រុមហ៊ុនដែលធ្វើអាជីវកម្មអាកាសចរស៊ីវិលនៅក្នុង ព្រះរាជាណាចក្រកម្ពុជា និងចុះបញ្ជីអាកាសយានស៊ីវិលគ្រប់ប្រភេទ ។

- ត្រួតពិនិត្យ វាយតម្លៃនូវបទពិសោធន៍ និងសមត្ថភាពរបស់ក្រុមអាកាសយានិកជាតិ និងអន្តរជាតិ ដែលកំពុងបំពេញការងារក្នុងប្រទេស ដើម្បីផ្តល់វិញ្ញាបនប័ត្រ ។
- តាមដានត្រួតពិនិត្យ ពីបទល្មើស កំហុសឆ្គងរបស់អាកាសយានិកជាតិ និងអន្តរជាតិ អ្នកបច្ចេកទេសរោងជាង អ្នកបច្ចេកទេសថែរក្សាអាកាសយាន ដើម្បីពិន័យ និងដកអភ័យឯកសិទ្ធិ ។
- ស្រាវជ្រាវគ្រោះថ្នាក់អាកាសយាន ។
- ត្រួតពិនិត្យ និងចេញបទបញ្ជាពីលក្ខណៈបច្ចេកទេសអាកាសយានជូនម្ចាស់អាកាសយានស៊ីវិល ។
- រៀបចំបទប្បញ្ញត្តិលើផ្នែកត្រួតពិនិត្យលទ្ធភាពហោះហើរ និងត្រួតពិនិត្យការងារអនុវត្ត ។

**មាត្រា ៧.-**

នាយកដ្ឋានវិស្វកម្មអេឡិចត្រូនិកទទួលបន្ទុក :

- គ្រប់គ្រងប្រព័ន្ធឧបករណ៍វិទ្យុអេឡិចត្រូនិក ដែលបំរើអោយសេវាកម្មចរាចរដែនអាកាស នៅក្នុងដែនអាកាសកម្ពុជា និងគ្រប់បណ្តាចំណតអាកាសយានដ្ឋានស៊ីវិល ។
- ធ្វើផែនការអភិវឌ្ឍន៍ប្រព័ន្ធវិទ្យុអេឡិចត្រូនិកទៅតាមតំរូវការ និងការអភិវឌ្ឍរបស់វិស័យអាកាស ចរណ៍អន្តរជាតិ ។
- គ្រប់គ្រង និងត្រួតពិនិត្យលើការប្រើប្រាស់រលកសញ្ញាវិទ្យុអេឡិចត្រូនិកគ្រប់ប្រភេទ ដែលបំរើអោយសេវាកម្មចរាចរដែនអាកាស និងរលកសញ្ញាវិទ្យុរំខានដោយអនុលោមតាមបទដ្ឋានរបស់អង្គការ អាកាស ចរណ៍ស៊ីវិលអន្តរជាតិ (ICAO) ។
- រៀបចំចងក្រងបទដ្ឋានបច្ចេកទេសលើសេវាកម្មថែរក្សា ប្រើប្រាស់ឧបករណ៍វិទ្យុអេឡិចត្រូនិកដោយ អនុលោមតាមកិរិតនិយាមរបស់សហគមន៍ទូរគមនាគមន៍អន្តរជាតិ (ITU) និងអង្គការអាកាសចរណ៍ ស៊ីវិលអន្តរជាតិ (ICAO) ។
- សហការសុំជំនួយពីសហគមន៍អន្តរជាតិ ដើម្បីបង្កើតមជ្ឈមណ្ឌលគ្រប់គ្រងដែនអាកាស (ACC) និង អនុវត្តការបញ្ជានាំផ្លូវដោយប្រព័ន្ធទាក់ទង នាំផ្លូវត្រួតពិនិត្យ (CNS) និងប្រព័ន្ធផ្កាយរណប (GPS) ។

**មាត្រា ៨.-**

នាយកដ្ឋានវិស្វកម្មអាកាសយានដ្ឋានទទួលបន្ទុក :

- ជួសជុល និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានស៊ីវិលដែលមានស្រាប់ តាមបទដ្ឋានរបស់ អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ (ICAO) សមាគមដឹកជញ្ជូនផ្លូវអាកាសអន្តរជាតិ (IATA) ។

- គ្រប់គ្រងការងារជួសជុល ថែរក្សាអាកាសយានដ្ឋាន និងផ្នែកដែលទទួលខុសត្រូវដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ។
- រៀបចំបទដ្ឋានត្រួតពិនិត្យផ្ទៃកំណត់កំពស់ឧបសគ្គនៃអាកាសយានដ្ឋាន និងតំបន់ជុំវិញព្រមទាំងគ្រប់គ្រង និងការពារ បរិដ្ឋានដែលពាក់ព័ន្ធ នឹងអាកាសយានដ្ឋានស៊ីវិល ។
- សិក្សាស្រាវជ្រាវអំពីភូមិសាស្ត្រ និងតំរូវការប្រើប្រាស់នៃអាកាសយានដ្ឋានស៊ីវិលក្នុងព្រះរាជាណាចក្រកម្ពុជា ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។
- កសាងប្លង់មេ និងកសាងទិសដៅនៃគំរោងនីតិសម្បទា និងគំរោងអភិវឌ្ឍន៍អាកាសយានដ្ឋានតាមផែនការមេ ។
- ត្រួតពិនិត្យ និងតាមដានរាល់គំរោងអភិវឌ្ឍន៍អាកាសយានដ្ឋានដែលវិនិយោគ ។
- សិក្សាតាមដានស្វែងយល់លើការប្រើប្រាស់អាគារ និងស្ថានីយ៍អ្នកដំណើរ ដើម្បីលើកទិសដៅនិង គ្រោងការ ពង្រីកអោយបានទាន់ពេលវេលា ។

**មាត្រា ៩.-**

នាយកដ្ឋានដឹកជញ្ជូនផ្លូវអាកាសទទួលបន្ទុក :

- គ្រប់គ្រង និងត្រួតពិនិត្យក្រុមហ៊ុនអាកាសចរណ៍ និងក្រុមហ៊ុនដែលពាក់ព័ន្ធដទៃទៀតលើការគោរពច្បាប់ បទប្បញ្ញត្តិ និងអនុសញ្ញាអន្តរជាតិនានាដែលពាក់ព័ន្ធដល់វិស័យអាកាសចរស៊ីវិល ។
- រៀបចំ និងអនុវត្តកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស និងអនុស្សារណៈដែលព្រមព្រៀងគ្នាជាមួយប្រទេសនានា ។
- គ្រប់គ្រងឯកសារ តម្លៃពន្ធសេវាកម្ម ត្រួតពិនិត្យការងារដឹកជញ្ជូនតាមផ្លូវអាកាសក្នុង និងក្រៅប្រទេសសរុបទិន្នន័យ និងសិក្សាទីផ្សារសំរាប់ការងារដឹកជញ្ជូនតាមផ្លូវអាកាស ។
- ត្រួតពិនិត្យការធានារ៉ាប់រងតាមផ្លូវអាកាសអន្តរជាតិ អោយស្របតាមអនុសញ្ញាវ៉ាស្សូវី និងការធានារ៉ាប់រងតាមផ្លូវអាកាសក្នុងស្រុកអោយតាមបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ១០.-**

នាយកដ្ឋានសន្តិសុខទទួលបន្ទុក :

- គ្រប់គ្រង និងការពារសន្តិសុខសុវត្ថិភាព និងចាត់វិធានការណ៍ទប់ស្កាត់នូវរាល់អំពើរំលោភបំពានបំផ្លិច បំផ្លាញដល់វិស័យអាកាសចរស៊ីវិល ដោយសហការជាមួយបណ្តាស្ថាប័នអាជ្ញាធរមានសមត្ថកិច្ច ។

- គោរពប្រតិបត្តិនូវសារាចរ សេចក្តីសំរេចផ្សេងៗ ដែលរាជរដ្ឋាភិបាលបានកំណត់ និងឧបសម្ព័ន្ធទី១៧ របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO) ។
- ត្រួតពិនិត្យ និងកំណត់អំពីព្រំខ័ណ្ឌការធ្វើអាជីវកម្មក្នុងប្រទេស និងក្រៅប្រទេសព្រមទាំងធានាសន្តិសុខ សុវត្ថិភាពដល់គ្រប់ចំណតយន្តហោះ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ។
- កំណត់អំពីលក្ខណៈបច្ចេកទេស រាល់ឧបករណ៍សំរាប់ឆែកឆេរ ត្រួតពិនិត្យនៅតាមបណ្តាអាកាសយាន ដ្ឋានអោយស្របតាមនិយាមអន្តរជាតិ ។

**មាត្រា ១១.-**

នាយកដ្ឋានផែនការនីតិកម្មទទួលបន្ទុក :

- រៀបចំ គ្រប់គ្រង និងសំរបសំរួល ពតិមាន ប្រព័ន្ធទិន្នន័យ ស្ថិតិ សេដ្ឋកិច្ច និងកំណត់យុទ្ធសាស្ត្រនិង កម្មវិធីអភិវឌ្ឍន៏វិស័យអាកាសចរណ៏លើគ្រប់ផ្នែកទាំងអស់ ។
- រៀបចំ ត្រួតពិនិត្យ និងកែសំរួលផែនការជាអាទិ៏ កម្មវិធីវិនិយោគសាធារណៈ ផែនការសេដ្ឋកិច្ចផែនការប្រចាំអនុតំបន់វិសាលភាពទន្លេមេគង្គ ផែនការប្រចាំតំបន់អាស៊ាន ដោយឈរលើមូលដ្ឋានយុទ្ធសាស្ត្រ និងកម្មវិធីអភិវឌ្ឍន៏វិស័យអាកាសចរណ៏ ។
- គ្រប់គ្រងសំរបសំរួល គំរោងសហប្រតិបត្តិការជាតិអន្តរជាតិ គ្រប់រូបភាពដែលពាក់ព័ន្ធដល់កិច្ចអភិវឌ្ឍន៏ វិស័យអាកាសចរណ៏ និងតាមដានត្រួតពិនិត្យការអនុវត្ត ។
- គ្រប់គ្រង ត្រួតពិនិត្យការអនុវត្ត និងផ្តល់យោបល់លើរាល់កិច្ចព្រមព្រៀង កិច្ចសន្យារបស់ក្រុមហ៊ុន សម្បទានពាណិជ្ជកម្ម អាជីវកម្ម ។

**មាត្រា ១២.-**

អាកាសយានដ្ឋានអន្តរជាតិពោធិចិនតុងមានឋានៈស្មើនាយកដ្ឋាន ទទួលបន្ទុក :

- អនុវត្តការងារត្រួតពិនិត្យ គ្រប់គ្រង និងបំរើជាក់ស្តែងសេវាកម្មចរាចរដែនអាកាស ។
- ការពារសន្តិសុខ សុវត្ថិភាពជុំវិញ និងក្នុងអាកាសយានដ្ឋាន ដោយអនុវត្តទៅតាមឧបសម្ព័ន្ធទី១៧របស់ អង្គការអាកាសចរណ៏ស៊ីវិលអន្តរជាតិ ។
- ត្រួតពិនិត្យ បូកសរុបការងារដឹកជញ្ជូនចេញ និងចូលតាមច្រកអាកាសយានដ្ឋាន ។

## ជំពូក ៤

## អាកាសយានដ្ឋានមូលដ្ឋាន

**មាត្រា ១៣.-**

អាកាសយានដ្ឋានខេត្ត ក្រុងទទួលបន្ទុកអនុវត្តសំរបសំរួលសកម្មភាព របស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ។

អាកាសយានដ្ឋានមូលដ្ឋានដែលមាន : អាកាសយានដ្ឋានសៀមរាប បាត់ដំបង កងកេង កោះកុង ស្ទឹង ត្រែង រតនគិរី និងមណ្ឌលគិរី ។ ការរៀបចំ និងការប្រព្រឹត្តទៅ របស់អាកាសយានដ្ឋានមូលដ្ឋានមានចែងនៅក្នុងអនុក្រឹត្យមួយដោយ ឡែក ។

## ជំពូក ៥

## អធិការដ្ឋាន

### មាត្រា ១៤.-

អធិការដ្ឋានរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលទទួលបន្ទុក :

- ធ្វើអធិការកិច្ចជាប្រចាំទៅលើរាល់ដំណើរការទាំងឡាយរបស់ស្ថាប័ន អង្គភាពក្រោមឱវាទនៃរដ្ឋលេខា ធិការដ្ឋានអាកាសចរស៊ីវិល ។
- ធ្វើរបាយការណ៍ជូនអនុរដ្ឋលេខាធិការ ស្តីពីការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទ ដែលធ្វើអធិការកិច្ចហើយនោះ និងពីមធ្យោបាយកែលំអ ។
- ប្រតិបត្តិភារកិច្ចតាមការ ដែលអនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានប្រគល់ ទុកចិត្ត ។

អធិការដ្ឋាន ដឹកនាំដោយអធិការមួយរូប អមដោយអធិការរងជាជំនួយការ ។

## ជំពូក ៦

## នាយកដ្ឋានរដ្ឋបាល បុគ្គលិក

### មាត្រា ១៥.-

នាយកដ្ឋានរដ្ឋបាល បុគ្គលិកទទួលបន្ទុក :

ក- ក្នុងវិស័យរដ្ឋបាល :

- សំរបសំរួលសកម្មភាពគ្រប់ផ្នែករបស់រដ្ឋលេខាធិការដ្ឋាននៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាល និង អង្គភាពមូលដ្ឋានក្រោមឱវាទ ។
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់រដ្ឋលេខាធិការដ្ឋាន ។ ធានាប្រសិទ្ធភាពសុវត្ថិភាពរដ្ឋបាល និងគ្រប់គ្រងការងារសង្គមរបស់រដ្ឋលេខាធិការដ្ឋាន ។
- សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់រដ្ឋលេខាធិការដ្ឋាន

ខ- ក្នុងវិស័យគ្រប់គ្រងបុគ្គលិក និងហិរញ្ញវត្ថុ

- គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងាររាជការរបស់រដ្ឋលេខាធិការដ្ឋាន ដោយទំនាក់ទំនង និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។
- រៀបចំរាល់លិខិតរដ្ឋបាល សំរាប់ការគ្រប់គ្រងអាជីព ។
- ធ្វើកម្មវិធីតំណែងឯកទេស និងធនធានមនុស្សរបស់រដ្ឋលេខាធិការដ្ឋាន ។
- វាយតម្លៃតំរូវការក្នុងការបណ្ដុះបណ្ដាលដំបូង និងបន្តដោយទំនាក់ទំនង និងរដ្ឋលេខាធិការដ្ឋានមុខ ងារសាធារណៈ និងអនុវត្តនយោបាយនោះ ។
- រៀបចំស្ថិតិលើការងារគ្រប់គ្រង និងតារាងពតិមានប្រតិបត្តិ ។
- រៀបចំបណ្ដុះបណ្ដាលជំនាញវិស័យអាកាសចរណ៍តាមរយៈជំនួយអន្តរជាតិ ។

## ជំពូក ៧

## នាយកដ្ឋានផ្គត់ផ្គង់ ហិរញ្ញវត្ថុ

**មាត្រា ១៦.-**

នាយកដ្ឋានផ្គត់ផ្គង់ ហិរញ្ញវត្ថុទទួលបន្ទុក :

- លើកគំរោងថវិការដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងតាមដានរំលឹកពីការប្រតិបត្តិ ។
- ប្រមូលផ្តុំ និងសំរបសំរួលជំពូកថវិកា ។
- តាមដានរំលឹកការគ្រប់គ្រងគណនីពិសេស ។
- គ្រប់គ្រងចំណូល ចំណាយអោយបានសមស្របតាមច្បាប់ហិរញ្ញវត្ថុ ។
- ប្រមូលផ្តុំ និងសំរបសំរួលរាល់ចំណាយរបស់រដ្ឋលេខាធិការដ្ឋាន ។
- គ្រប់គ្រងបន្ទុកគណនីនៃការអនុវត្តលទ្ធកម្មសាធារណៈ ។
- ប្រមូលផ្តុំតំរូវការ ធ្វើកម្មវិធីចំណាយគ្រប់គ្រងការរៀបចំជួសជុលសំភារៈ និងបរិក្ខាររបស់រដ្ឋលេខាធិការដ្ឋាន ។
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ ។
- គ្រប់គ្រងយានដ្ឋាន និងយានយន្តរបស់រដ្ឋដែលប្រគល់ជូន រដ្ឋលេខាធិការដ្ឋាន ព្រមទាំងធ្វើកម្មវិធីចំណាយ និងបែងចែកប្រេងឥន្ទនៈ និងគ្រឿងបន្លាស់ ។
- ទទួល និងបែងចែកបរិក្ខារជូនដល់បណ្ដាអង្គភាពក្រោមឱវាទ ។
- ពតិមានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី ។

## ជំពូក ៨
## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា ១៧.-**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញ វត្ថុ តាមល័ក្ខខ័ណ្ឌនៃបទបញ្ញោកំណត់ក្នុង អនុក្រឹត្យលេខ៨១ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការ បង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្តាក្រសួង ។

## ជំពូក ៩
## អវសានប្បញ្ញត្តិ

**មាត្រា ១៨.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលនៅរដ្ឋបាលកណ្តាល ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋ មន្ត្រី។

**មាត្រា ១៩.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ជាអាទិ៍ អនុក្រឹត្យ លេខ ៦០ អនក្រ ចុះថ្ងៃ ០៧ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការបង្កើតអាជ្ញាធរអភិវឌ្ឍន៍ អាកាសយានដ្ឋាន ត្រូវទុកជានិរាករណ៍។

**មាត្រា ២០.-**

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល រដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំងអស់ ដែលមានការពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុ ក្រឹត្យតាមភារកិច្ចរៀង១ខ្លួន។

**មាត្រា ២១.-**

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ ១៩៩៨

**នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី២**

**អ៊ឹង ហួត** | **ហ៊ុន សែន**

បានជំរាបជូន

នាយករដ្ឋមន្ត្រីទី ១

សម្តេចនាយករដ្ឋមន្ត្រីទី ២

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**សុខ អាន** **ណាឌី តាន់**

ឧបសម្ព័ន្ធអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ១៩៩៨

# អង្គការលេខរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវល

